ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងផែនការ

# សុន្ទរកថាស្វាគមន៍ និងរបាយការណ៍សង្ខេបពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ របស់ក្រសួងផែនការ

ថ្ងៃចន្ទ ១៥រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៨
ខែមេសា ឆ្នាំ២០២៤ នៅទីស្តីការក្រសួងផែនការ

**- ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ**
**- ឯកឧត្តម លោកជំទាវ អគ្គលេខាធិការ អគ្គនាយក**
**- លោក លោកស្រី តំណាងដៃគូអភិវឌ្ឍ ភ្ញៀវកិត្តិយស និងសមាជិក សមាជិកា**

**ជាទីរាប់អាន!**

ថ្ងៃនេះ ជាថ្ងៃពោរពេញដោយភាពសប្បាយរីករាយនិងមោទនភាពក្រៃលែង ដែលយើងបានរៀបចំសន្និបាតបូកសរុបការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ របស់ក្រសួងផែនការ ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងផែនការ ព្រមទាំងតំណាងក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍនានា ដែលបានឆ្លៀតពេលវេលាដ៏មានតម្លៃអញ្ជើញចូលរួមក្នុងសន្និបាតដ៏មានសារៈសំខាន់នេះ។

ក្រសួងផែនការ គឺជាសេនាធិការរបស់រាជរដ្ឋាភិបាលលើបេសកកម្មដឹកនាំ សម្របសម្រួល និងគ្រប់គ្រងការងារវិស័យផែនការ ស្ថិតិ និងប្រជាជន និងអភិវឌ្ឍន៍ ដើម្បីការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ក្រសួងផែនការមានភារកិច្ចដឹកនាំ រៀបចំ និងកំណត់ចក្ខុវិស័យគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធីអាទិភាពសម្រាប់អភិវឌ្ឍទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ, ការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្ត, ការងារផលិត ចងក្រង និងគ្រប់គ្រងទិន្នន័យនិងស្ថិតិជាតិ តាមរយៈការធ្វើជំរឿននិងអង្កេត ព្រមទាំងផ្តល់ការគាំទ្របច្ចេកទេសទាក់ទងនឹងការធ្វើអង្កេតតាមវិស័យ, និងសិក្សាស្រាវជ្រាវអំពីស្ថានភាពសង្គម-សេដ្ឋកិច្ច សង្គម-ប្រជាសាស្ត្រ សង្គម-វប្បធម៌ និងសង្គម-បរិស្ថាន ។ល។

យោងតាមអនុក្រឹត្យលេខ១៤៤ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ មានខុទ្ទកាល័យ អគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកដ្ឋានផែនការ វិទ្យាស្ថានជាតិស្ថិតិ អគ្គលេខាធិការដ្ឋានប្រជាជន និងអភិវឌ្ឍន៍ អគ្គាធិការដ្ឋាន សាលាជាតិផែនការ និងស្ថិតិ នាយកដ្ឋានសវនកម្មផ្ទៃក្នុង និងអង្គភាពលទ្ធកម្ម រួមទាំងមន្ទីរផែនការរាជធានី ខេត្ត ដែលមានបេសកកម្មបំពេញភារកិច្ចលើវិស័យផែនការ វិស័យស្ថិតិ វិស័យប្រជាជន និងអភិវឌ្ឍន៍ និងការបណ្តុះបណ្តាល។ វិស័យអាទិភាពរបស់ក្រសួងផែនការ រួមមាន៖

## ក. ការងារវិស័យផែនការ

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គឺជាឯកសារផែនការយ៉ាងសំខាន់សម្រាប់អនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា, គោលដៅ និងអនុសញ្ញាសាកល ដែលកម្ពុជាបានផ្តល់សច្ចាប័ន, ក្នុងគោលបំណងអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជា។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ត្រូវបានរៀបចំចំនួន ៥លើក ចាប់ពីឆ្នាំ១៩៩៦ មក។ បច្ចុប្បន្នក្រសួងផែនការ កំពុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ សម្រាប់អាណត្តិកាល ២០២៤-២០២៨។

កម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ដែលបានចាប់ផ្តើមរៀបចំតាំងពីឆ្នាំ១៩៩៦ គឺជាឧបករណ៍មួយសម្រាប់អនុវត្តគោលនយោបាយអាទិភាពជាតិ ដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងជាធាតុចូលសម្រាប់ការរៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។ កម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល លើកទី៣០ សម្រាប់ឆ្នាំ២០២៥-២០២៧ ទើបទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រី នៅសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤។

គោលដៅអភិវឌ្ឍប្រកបដោយចីរភាពសាកល ត្រូវបានធ្វើមូលដ្ឋាននីយកម្មក្នុងបរិការណ៍កម្ពុជា មកជាក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ឆ្នាំ២០១៦-២០៣០។ ក្របខ័ណ្ឌនេះ ត្រូវបានតាមដានត្រួតពិនិត្យ និងវាយតម្លៃពីលទ្ធផលនៃការសម្រេចបាន តាមរយៈរបាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្តចំនួន ២(ពីរ)លើក ឆ្នាំ២០១៩ និងឆ្នាំ២០២៣។

ការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៦ ដើម្បីកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ។ បច្ចុប្បន្ននេះ ប្រមាណ១,២លានគ្រួសារ ទទួលបានបណ្ណសមធម៌ និងបណ្ណសម្គាល់គ្រួសារងាយរងហានិភ័យ ដែលគ្របដណ្តប់លើប្រជាជនប្រមាណ៥លាននាក់។ ទិន្នន័យពីកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ត្រូវបានប្រើប្រាស់ក្នុងកម្មវិធីគាំពារសង្គម និងជំនួយសង្គមផ្សេងៗ។ បច្ចុប្បន្ន ក្រសួងផែនការកំពុងគិតគូរអំពីការធ្វើនវានុវត្តន៍ និងបរិវត្តកម្មឌីជីថលនៃនីតិវិធីកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ សំដៅបង្កើនប្រសិទ្ធភាព កាត់បន្ថយពេលវេលា ផ្តល់ជូនទិន្នន័យដែលមានបច្ចុប្បន្នភាព និងកាត់បន្ថយការចំណាយក្នុងការអនុវត្តផងដែរ។

ក្រៅពីនេះ មានការងារគាំទ្រមួយចំនួនទៀត ដូចជា ការងារវាស់វែងភាពក្រីក្ររបស់កុមារ និងប្រជាជនកម្ពុជា ដោយផ្អែកលើចំណូលចំណាយ និងផ្អែកលើពហុសមាសភាគ, ការងារលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភ តាមរយៈការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ ដើម្បីលើកកម្ពស់អាហារូបត្ថម្ភរបស់ប្រជាជន ជាពិសេសស្ត្រី និងកុមារ, ការងារផែនការនៅថ្នាក់ក្រោមជាតិ ដែលជាយន្តការសម្របសម្រួលដល់ការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្នុងការគាំទ្រដល់ដំណើរការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល នៅថ្នាក់ក្រោមជាតិ និងការគ្រប់គ្រងប្រព័ន្ធទិន្នន័យមូលដ្ឋានឃុំ សង្កាត់ (CDB), និងប្រព័ន្ធទិន្នន័យគ្រប់គ្រងគម្រោង (SPD) ។

## ខ. ការងារវិស័យស្ថិតិ

វិទ្យាស្ថានជាតិស្ថិតិ ជាស្ថាប័នស្ថិតិជាតិផ្លូវការរបស់រាជរដ្ឋាភិបាលទទួលបន្ទុកអភិវឌ្ឍស្ថិតិជាតិ ដោយផ្អែកលើគោលការណ៍នៃភាពត្រឹមត្រូវ ភាពឯករាជ្យ ភាពសត្យានុម័ត ភាពគួរទុកចិត្តបាន ភាពសំខាន់ និងភាព

ទាន់ពេលវេលា។ វិទ្យាស្ថានជាតិស្ថិតិបង្កើតនិងគ្រប់គ្រងប្រព័ន្ធស្ថិតិជាតិរួមបញ្ចូលគ្នា ដែលគ្របដណ្តប់ស្ថិតិផ្លូវការដែលបានចាត់តាំងទាំងអស់របស់ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល និងមានភារកិច្ចប្រមូល កែច្នៃ ចងក្រង និងវិភាគទិន្នន័យនិងស្ថិតិ, គ្រប់គ្រង បោះពុម្ព និងផ្សព្វផ្សាយស្ថិតិផ្លូវការ។

ក្រៅពីការងារច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងារស្ថិតិ និងការងារសម្របសម្រួលនិងគ្រប់គ្រងប្រព័ន្ធស្ថិតិជាតិ វិទ្យាស្ថានជាតិស្ថិតិមានភារកិច្ចអនុវត្តការងារផលិតទិន្នន័យជាច្រើន ដូចជា៖

១- ការងារជំរឿន ដែលមានជំរឿនប្រជាជន ជំរឿនសេដ្ឋកិច្ច និងជំរឿនកសិកម្ម។

២- ការងារអង្កេត ដែលមានអង្កេតចន្លោះជំរឿនប្រជាជន អង្កេតចន្លោះជំរឿនសេដ្ឋកិច្ច អង្កេតចន្លោះជំរឿនកសិកម្ម អង្កេតកសិកម្មប្រចាំឆ្នាំ អង្កេតសេដ្ឋកិច្ចនិងសង្គមកិច្ចកម្ពុជា និងអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា។

៣- ការងារគណនេយ្យជាតិ និងការងារសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់។

## គ. ការងារវិស័យប្រជាជននិងអភិវឌ្ឍន៍

អគ្គលេខាធិការដ្ឋានប្រជាជននិងអភិវឌ្ឍន៍ មានភារកិច្ចអនុវត្តការងារវិស័យប្រជាជន និងអភិវឌ្ឍន៍ ដែលការងារអាទិភាពរួមមាន ការងារគោលនយោបាយជាតិប្រជាជន, ការងារផ្សព្វផ្សាយ, ការងារបណ្តុះបណ្តាល, ការងារអភិវឌ្ឍន៍សហគមន៍, ការងារស្រាវជ្រាវនិងអភិវឌ្ឍន៍, និងការងារកិច្ចសហប្រតិបត្តិការពាក់ព័ន្ធនឹងវិស័យប្រជាជននិងអភិវឌ្ឍន៍។

១-អគ្គលេខាធិការដ្ឋានប្រជាជននិងអភិវឌ្ឍន៍ រៀបចំ ផ្សព្វផ្សាយ និងតាមដានត្រួតពិនិត្យ ការអនុវត្តគោលនយោបាយជាតិប្រជាជន និងធ្វើបច្ចុប្បន្នភាពគោលនយោបាយជាតិប្រជាជន។ គោលនយោបាយជាតិប្រជាជន ២០១៦-២០៣០ គឺជាឯកសារគោលនយោបាយរយៈពេលវែង និងមានលក្ខណៈពហុវិស័យ ដែលបង្ហាញអំពីបញ្ហាគន្លឹះរបស់ប្រជាជន, ទំនាក់ទំនងរវាងប្រជាជន និងការអភិវឌ្ឍ, និងវិធានការគោលនយោបាយនានា ដើម្បីដោះស្រាយបញ្ហាប្រជាជនដែលបាននិងកំពុងកើតមាន។ គោលនយោបាយជាតិប្រជាជនផ្តោតអាទិភាពខ្ពស់លើការលើកកម្ពស់ការអភិវឌ្ឍមូលធនមនុស្ស និងការវិនិយោគកាន់តែច្រើនជាងមុន នៅក្នុងវិស័យអប់រំនិងសុខាភិបាល ដោយយកចិត្តទុកដាក់ជាសំខាន់ទៅលើយុវជន។

២-អគ្គលេខាធិការដ្ឋានប្រជាជន និងអភិវឌ្ឍន៍ បានបណ្តុះបណ្តាលធនធានមនុស្សជារៀងរាល់ឆ្នាំ ដល់មន្ត្រីផ្ទៃក្នុងអគ្គលេខាធិការដ្ឋាន និងមន្ត្រីមន្ទីរផែនការរាជធានី ខេត្ត ជាពិសេសមន្ត្រីការិយាល័យប្រជាជន និងអភិវឌ្ឍន៍ ក្នុងគោលបំណងលើកកម្ពស់ដំណេះដឹង និងជំនាញផ្នែកប្រជាសាស្ត្រ និងគោលនយោបាយប្រជាជន។

៣-ការងារអភិវឌ្ឍន៍សហគមន៍ គឺជាអាទិភាពរបស់រាជរដ្ឋាភិបាល ក៏ដូចជារបស់អង្គការសហប្រជាជាតិ ដោយឈរលើគោលការណ៍ "មិនទុកនរណាម្នាក់ចោល"។ ការប្រមូល ការចងក្រង និងការគ្រប់គ្រងទិន្នន័យសហគមន៍ គឺជាការងារអាទិភាពរបស់អគ្គលេខាធិការដ្ឋានប្រជាជននិងអភិវឌ្ឍន៍ ដើម្បីបង្កើតជាមូលដ្ឋានទិន្នន័យសហគមន៍កម្ពុជា (Cambodia Community Database) ដែលមានគុណភាពសម្រាប់ជាប្រយោជន៍ដល់អ្នករៀបចំគោលនយោបាយ ផែនការ និងអ្នកសិក្សាស្រាវជ្រាវ។ សៀវភៅណែនាំស្តីពីការអភិវឌ្ឍសហគមន៍លំនៅឋានបណ្តោះអាសន្ន គឺជាឧបករណ៍ដ៏សំខាន់ សម្រាប់ជួយសម្រួលដល់ស្ថាប័នពាក់ព័ន្ធនានា អាជ្ញាធរមូលដ្ឋាន ដៃគូអភិវឌ្ឍនានា និងសង្គមស៊ីវិល យកទៅប្រើប្រាស់ក្នុងការរៀបចំ កែលម្អ និងអភិវឌ្ឍសហគមន៍លំនៅឋានបណ្តោះអាសន្នឱ្យកាន់តែប្រសើរឡើង និងមានប្រសិទ្ធភាពខ្ពស់។

៤-ការងារស្រាវជ្រាវនិងអភិវឌ្ឍន៍ គឺជាការងារចាំបាច់ និងបន្ទាន់របស់អគ្គលេខាធិការដ្ឋានប្រជាជននិងអភិវឌ្ឍន៍ ព្រោះការងារស្រាវជ្រាវនេះ នឹងរកឃើញពីចំណុចខ្លាំង ចំណុចខ្សោយ និងបញ្ហាប្រឈមនៃការអនុវត្តគោលនយោបាយនានា។ លើសពីនេះទៀត ការងារស្រាវជ្រាវនេះ នឹងឆ្លុះបញ្ចាំងពីការវិវត្តនៃសង្គម-សេដ្ឋកិច្ច, សង្គម-ប្រជាសាស្ត្រ, សង្គម-វប្បធម៌និងសាសនា, និងសង្គម-បរិស្ថាន ដែលអាចជាមូលដ្ឋានព័ត៌មានដ៏មានសារៈសំខាន់សម្រាប់ធ្វើបច្ចុប្បន្នភាព ឬកែសម្រួលគោលនយោបាយ និងផែនការអភិវឌ្ឍន៍នានា ទាន់ពេលវេលា និងមានប្រសិទ្ធភាព។

៥-ការរៀបចំទិវាប្រជាជនពិភពលោកនិងវេទិកាផ្សេងៗដែលទាក់ទងនឹងប្រជាជននិងអភិវឌ្ឍន៍ដើម្បីឆ្លុះបញ្ចាំងឱ្យឃើញពីការខិតខំរបស់រាជរដ្ឋាភិបាល លើការគិតគូរពីស្ថានភាពជីវភាពប្រជាជន ឱ្យកាន់តែមានភាពប្រសើរឡើង និងការគិតគូរអំពីសិទ្ធិនិងជម្រើសរបស់ប្រជាជន ពិសេសស្ត្រីនិងក្មេងស្រី។

## ឃ. វិស័យរដ្ឋបាលនិងកិច្ចការទូទៅ

ក្នុងបរិការណ៍នៃកំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ក្រសួងផែនការបានអនុវត្តនិងសម្របសម្រួលការងារសំខាន់ៗ ដូចខាងក្រោម៖

១- ការកែទម្រង់ និងលើកកម្ពស់សមត្ថភាពស្ថាប័ននិងមន្ត្រីរាជការ។

២- ការគ្រប់គ្រងក្របខ័ណ្ឌនិងការអភិវឌ្ឍអាជីពមន្ត្រីរាជការ។

៣- ការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ។

៤- ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

៥- កិច្ចសហប្រតិបត្តិការអន្តរជាតិ។

## ង. វិស័យបណ្តុះបណ្តាល

រាជរដ្ឋាភិបាល បានដំឡើងកម្រិតពីមជ្ឈមណ្ឌលបណ្តុះបណ្តាលផែនការ-ស្ថិតិ ទៅជាសាលាជាតិផែនការ និងស្ថិតិ ដែលជាគ្រឹះស្ថានឧត្តមសិក្សាផ្តល់ការអប់រំនិងបណ្តុះបណ្តាលកម្រិតឧត្តមសិក្សា និងសុក្រឹតការវិក្រឹតការ ក្នុងវិស័យផែនការនិងស្ថិតិ លើជំនាញផែនការអភិវឌ្ឍន៍ ស្ថិតិអនុវត្តន៍ ស្ថិតិប្រជាសាស្ត្រ និងការតាមដានត្រួតពិនិត្យនិងវាយតម្លៃ។ល។ សាលាជាតិផែនការ និងស្ថិតិ មានមហាវិទ្យាល័យរួមមាន៖ ១). មហាវិទ្យាល័យផែនការអភិវឌ្ឍន៍, ២). មហាវិទ្យាល័យស្ថិតិ និង៣). មជ្ឈមណ្ឌលបណ្តុះបណ្តាល ស្រាវជ្រាវ និងអភិវឌ្ឍន៍ ដែលបាននិងកំពុង ផ្តល់ការអប់រំ និងបណ្តុះបណ្តាលជំនាញវិស័យផែនការ ស្ថិតិ និងប្រជាសាស្ត្រ ដើម្បីឆ្លើយតបតាមតម្រូវការរីកចម្រើននៃប្រទេសជាតិ ការកែទម្រង់រដ្ឋបាលសាធារណៈ យុទ្ធសាស្ត្រចតុកោណ និងយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាល។

បច្ចុប្បន្ន សាលាជាតិផែនការ និងស្ថិតិ បាននិងកំពុងបណ្តុះបណ្តាលនិស្សិត និងមន្ត្រីរាជការ សរុបចំនួន ៥៨៣នាក់ (ស្ត្រី ១៣២នាក់ និងប្រុស ៤៥១នាក់) ដែលក្នុងនោះនិស្សិតជាមន្ត្រីរាជការមានសរុបចំនួន ៤៥២នាក់ សិក្សាកម្រិតបរិញ្ញាបត្រ និងកម្រិតបរិញ្ញាបត្រជាន់ខ្ពស់លើជំនាញផែនការអភិវឌ្ឍន៍ ស្ថិតិអនុវត្តន៍ ស្ថិតិប្រជាសាស្ត្រ និងការតាមដានត្រួតពិនិត្យនិងវាយតម្លៃ។ សាលាជាតិផែនការនិងស្ថិតិ ក៏បាននិងកំពុងរៀបចំគម្រោងស្រាវជ្រាវ និងគម្រោងអភិវឌ្ឍន៍។

### ច. វិស័យផែនការ ស្ថិតិ និងប្រជាជន នៅរាជធានី ខេត្ត

មន្ទីរផែនការរាជធានី ខេត្ត បំពេញការងារក្នុងនាមក្រសួងផែនការនៅថ្នាក់ក្រោមជាតិ និងជាសេនាធិការជូនគណៈអភិបាលរាជធានី ខេត្ត ដោយបានចូលរួមចំណែកយ៉ាងសកម្មក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលនៅថ្នាក់រាជធានី ខេត្ត លើការងារចម្បងៗ ដូចខាងក្រោមៈ

១- ការផ្តល់បច្ចេកទេស សម្របសម្រួលរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគសាធារណៈបីឆ្នាំ រំកិល រាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ ឃុំ/សង្កាត់។

២- ការគ្រប់គ្រងសម្របសម្រួលដំណើរការប្រមូលទិន្នន័យមូលដ្ឋានឃុំ/សង្កាត់ និងការរៀបចំជាឯកសារ ព័ត៌មានស្ថានភាព និងឯកសារពិន្ទុវិស័យឃុំ/សង្កាត់ ស្រុក/ក្រុង/ខណ្ឌ និងរាជធានី/ខេត្ត សម្រាប់បម្រើ ដល់ការងារកសាងផែនការគ្រប់វិស័យទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

៣- ការសម្របសម្រួលអនុវត្តនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ នៅតាម រាជធានី ខេត្ត។

៤- ការងារតាមដានត្រួតពិនិត្យការអនុវត្តគម្រោងថ្នាក់ក្រោមជាតិ។

៥- ការចូលរួមការងារជំរឿន អង្កេតផ្សេងៗ។

៦- ការងារស្រង់តម្លៃទំនិញទីផ្សារ និងការប្រមូលទិន្នន័យរៀបចំផលិតផលក្នុងស្រុកសរុបរាជធានី ខេត្ត។

៧- និងការងារប្រជាជននិងអភិវឌ្ឍន៍។

## **គណៈអធិបតី និងសមាជិក សមាជិកា អង្គសន្និបាតជាទីមេត្រី!**

២០២៣ គឺជាឆ្នាំបញ្ចប់នៃរាជរដ្ឋាភិបាលអាណត្តិទី៦ និងជាឆ្នាំចាប់ផ្តើមនៃរាជរដ្ឋាភិបាលអាណត្តិទី៧ ដែលកើតចេញពីការបោះឆ្នោតសាកល ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣។ រាជរដ្ឋាភិបាលនៅក្នុងអាណត្តិទី៧ បានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដោយមានបាវចនា កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព ដោយផ្តោតលើអាទិភាពគន្លឹះ គឺ មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យាឌីជីថល។

ថ្នាក់ដឹកនាំនិងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងផែនការ បាននិងកំពុងបន្តកិច្ចខិតខំអនុវត្តភារកិច្ចរបស់ខ្លួនបានយ៉ាងខ្ជាប់ខ្ជួន និងសម្រេចបាននូវសមិទ្ធផលការងារធំធេងជាច្រើន គួរជាទីមោទន។ គោលបំណងនៃសន្និបាតក្នុងរយៈពេល ២ថ្ងៃនេះ គឺដើម្បីពិនិត្យទៅលើសមិទ្ធផលការងារឆ្នាំ២០២៣ បញ្ហាប្រឈម និងការលើកទិសដៅការងារឆ្នាំ២០២៤ របស់ក្រសួងផែនការ សំដៅពង្រឹងសមត្ថភាព និងបង្កើនប្រសិទ្ធភាពការងារ របស់ស្ថាប័ននិងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់។

នៅក្នុងន័យនេះ ខ្ញុំសូមស្នើដល់អង្គសន្និបាតទាំងមូល យកចិត្តទុកដាក់ស្វែងយល់ និងពិភាក្សាឱ្យបានផុលផុសអំពីសមិទ្ធផលការងារឆ្នាំ២០២៣ និងបញ្ហាប្រឈមទាំងឡាយដែលបានជួបប្រទះ ដើម្បីរកដំណោះស្រាយសមស្រប និងលើកទិសដៅការងារសម្រាប់ឆ្នាំ២០២៤ ប្រកបដោយភាពបុរេសកម្ម សក្តិសិទ្ធភាព ប្រសិទ្ធភាព និងប្រសិទ្ធផល គ្រប់វិស័យការងាររបស់ក្រសួងផែនការ នៅក្នុងបរិបទនៃកំណែទម្រង់រដ្ឋបាលសាធារណៈស៊ីជម្រៅរបស់រាជរដ្ឋាភិបាលអាណត្តិទី៧នេះដើម្បីរួមចំណែកដឹកនាំប្រទេសកម្ពុជាចាកចេញពីចំណាត់ក្រុមប្រទេសអភិវឌ្ឍតិចតួចឱ្យបានជោគជ័យ។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរ បវរមហាប្រសើរ ជូនដល់គណៈអធិបតី សមាជិក សមាជិកា នៃអង្គសន្និបាតទាំងមូល សូមជួបប្រទះតែនឹងសេចក្តីសុខនិងសេចក្តីចម្រើនគ្រប់ប្រការ សូមមានសុខភាពល្អបរិបូណ៌ និងសុភមង្គលល្អក្នុងគ្រួសារ និងសូមសម្រេចបានជោគជ័យគ្រប់ភារកិច្ចដែលរាជរដ្ឋាភិបាល និងក្រសួងប្រគល់ជូន។

**ខ្ញុំសូមប្រកាសបើក អង្គសន្និបាតបូកសរុបការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ របស់ក្រសួងផែនការចាប់ពីពេលនេះតទៅ។**

**សូមអរគុណ**!